ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: ១៣៦ ប្រកស.....ប.ស្ក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "អូរខាំផា" ឃុំតាវែងលើ ស្រុកតាវែង ស្ថិតក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹងលេខ ២៩៥ សជណ.កស ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី ។

## សំ រេ ច

ប្រការ១:- រៀបចំសហគមន៍តំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ក្នុងឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី មានឈ្មោះថា "**សហគមន៍តំបន់ការពារធម្មជាតិអូរខាំផា** " ។

ប្រការ២:- សហគមន៍តំបន់ការពារធម្មជាតិអូរខាំផា នៃឧទ្យានជាតិវីរៈជ័យ ស្ថិតក្នុងភូមិសាស្ត្រ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី មានផ្ទៃដីពីរពាន់បីរយប៉ែតសិបពីរហិកតា កៅសិបមួយអារ និងដប់បួនសង់ចារ (**២៣៨២,៩១១៤ហិកតា**) ដូចបានកំណត់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេព្រំប្រទល់ ខាងក្រោម :

| ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|---|
| A | ផ្លូវឡានអូរកានាងប្រាស | ០៧៣៩៨៣៨ | ១៥៧១៧៥៦ |
| B | ផ្លូវឡានចេញពីអូរកានាងប្រាស | ០៧៤១៥១៦ | ១៥៧០៦៥០ |
| C | ជើងភ្នំហាលែន | ០៧៤០១៤៣ | ១៥៦៩៤៤៩ |
| D | ជើងភ្នំហាលែន | ០៧៣៩៦៣៦ | ១៥៦៩៦៧៩ |
| E | ជើងភ្នំហាលែន | ០៧៣៨៩៣៩ | ១៥៧០១៥២ |
| F | ជើងភ្នំហាលែន | ០៧៣៧៥៣៨ | ១៥៧១៤៥៥ |
| G | អូរតាវិញ | ០៧៣៦៨៩៧ | ១៥៧២៧៨៧ |
| H | អូរកាទ្រឹល | ០៧៣៦៩៣៧ | ១៥៧៣៥៣៦ |
| I | អូរភ្លុយ | ០៧៣៤៨៤៥ | ១៥៧៤៦៥៦ |
| J | អូរខាំផា | ០៧៣២៥៩៣ | ១៥៧៣៩៧៩ |

<u>ប្រការ៣:</u>- ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ**អូរខាំផា** នៃឧទ្យានជាតិវីរៈជ័យ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

<u>ប្រការ៤:</u>- អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថាន ខេត្តរតនៈគិរី នាយកឧទ្យានជាតិវីរៈជ័យ អង្គភាពពាក់ព័ន្ធ និងសហគមន៍តំបន់ការពារធម្មជាតិ**អូរខាំផា** ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*<u>ចំលងជូន:</u>*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាខេត្តរតនៈគិរី
- គំរោងគ្រប់គ្រងជីវៈចម្រុះ និងឧទ្យានជាតិវីរៈជ័យ
- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- ឯកសារ. កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា